សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីត្រីអាំង ដែលត្រីនៅក្នុងស្រុកខ្មែរយើងចែកចេញជា ២ ប្រភេទ ត្រីទឹកសាប និងត្រីទឹកប្រៃ។ ត្រីទឹកសាបសំដៅទៅលើត្រីដែលរស់នៅក្នុងទឹកទន្លេ ទឹកស្ទឹង ទឹកបឹង ទឹកព្រែក និងត្រីទឹកប្រៃសំដៅទៅលើត្រីដែលរស់នៅក្នុងសមុទ្រ។

រូបភាពទី ១ យើងឃើញមានបុរសម្នាក់ដែលគាត់មានវ័យ ឬក៏អាយុប្រហែលជា ១៨ ឆ្នាំ គាត់ពាក់អាវយឺតកមូល ដៃខ្លីពណ៌ពងមាន់ ជាមួយនឹងខោសជើងវែង និងស្បែកជើងប៉ាតាពណ៌ទឹកក្រូច។ គាត់កំពុងតែដើរនៅតាមផ្លូវដើម្បីត្រលប់ទៅផ្ទះរបស់គាត់វិញ ដែលផ្ទះរបស់គាត់គឺស្ថិតនៅក្នុងទីក្រុងមួយ ប្រហែលជាគាត់ទើបតែចេញមកពីកន្លែងធ្វើការ ឬក៏ប្រហែលជាគាត់ទើបតែ ទើបតែត្រលប់មកពីជួបពួកម៉ាករបស់គាត់នៅហាងកាហ្វេ ដើម្បី ដើម្បីជជែកគ្នាលេងអំពីការងារ។ អញ្ចឹងនៅពេលដែលគាត់ធ្វើការចប់ ឬក៏ជជែកជាមួយនឹងពួកម៉ាកចប់ អញ្ចឹងគាត់ក៏បានដើរត្រលប់ទៅផ្ទះរបស់គាត់វិញ។ ប៉ុន្តែមុនពេលត្រលប់ទៅផ្ទះ គាត់ត្រូវរកកន្លែងលក់ គាត់ត្រូវរកកន្លែងទិញម្ហូប និងបាយ ដើម្បីយកទៅញ៉ាំសម្រាប់អាហារពេលល្ងាចរបស់គាត់ ប្រហែលជាថ្ងៃនេះនៅផ្ទះរបស់គាត់មិនបានធ្វើម្ហូបទេ។

រូបភាពទី ២ នៅពេលដែលគាត់ដើរនៅតាមផ្លូវមួយសន្ទុះ គាត់ក៏បានប្រទះឃើញ គាត់ក៏បានប្រទះឃើញកន្លែងលក់ម្ហូបមួយកន្លែងនៅតាមផ្លូវ ដោយ ដោយយើងឃើញកន្លែងនោះគឺមានលក់ត្រីអាំងជាមួយនឹងបាយស។ យើងឃើញអ្នកលក់កំពុងតែអង្គុយអាំងត្រី ដោយអ្នកលក់យើងឃើញមានវ័យ ឬក៏អាយុប្រហែលជា ១៨ ឆ្នាំ ពាក់អាវ ពាក់អាវដៃខ្លី ពាក់អាវយឺតដៃខ្លី ពណ៌ស្វាយ ជាមួយនឹងខោសជើងវែង និងស្បែកជើងពណ៌ខ្មៅ។ អ្នកលក់គឺកំពុងតែអង្គុយអាំងត្រី និងនៅក្នុងដៃខាងស្តាំរបស់គាត់មានកាន់ចង្កឹះ ឬក៏ដែកដែលយើងហៅថាចន្នាស យើងហៅថាចន្នាស ប្រើសម្រាប់ យើងហៅថាចន្នាសឬក៏ប្រដាប់ចាប់ ប្រដាប់ចាប់ត្រី ប្រដាប់សម្រាប់ប្រែត្រី សម្រាប់ប្រែត្រី ពីព្រោះប្រសិនបើយើងអាំងត្រី យើងត្រូវប្រែត្រី យើងត្រូវប្រែត្រីចុះឡើង ពីព្រោះប្រសិនបើយើងមិនបានប្រែវាទេ ត្រីនោះនឹងអាចខ្លោច នឹងអាច នឹងអាចខ្លោច និងធ្វើឲ្យត្រីមានរសជាតិអត់ឆ្ងាញ់ មាន និងធ្វើឲ្យត្រីមានរសជាតិអត់ឆ្ងាញ់ និងពេលខ្លះនៅពេលដែលយើងប្រែវាចុះឡើងខ្លាំងពេក និងពេលខ្លះអាចធ្វើឲ្យត្រីនោះឆៅផងដែរ។ អញ្ចឹងយើងត្រូវ យើងត្រូវ នៅពេលដែលយើងអាំងត្រី យើងត្រូវ យើងត្រូវដាក់ភ្លើងល្មម និងយើងត្រូវប្រែវា កុំប្រែវារហ័សពេក នៅពេលដែលយើងមើលទៅឆ្អិនម្ខាងហើយ ចាំយើងប្រែវាម្ខាងទៀត ពីព្រោះប្រសិនបើយើងប្រែវាចុះឡើងក៏អាចធ្វើឲ្យត្រីនោះឆៅបានដែរ។ និងប្រសិនបើយើងអត់ ប្រសិនបើយើងអត់ប្រែវាទេ ទុកវារយៈពេលយូរ អាចធ្វើឲ្យត្រីនោះខ្លោចបាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងអ្នកលក់គាត់ត្រូវអង្គុយអាំងត្រីដោយយកចិត្តទុកដាក់ ពីព្រោះប្រសិនបើត្រីឆៅ ឬក៏ត្រីខ្លោច
អត់មានភ្ញៀវណាគាត់ចូលមកទិញទេ។ អញ្ចឹងអ្នកលក់គាត់អង្គុយអាំងត្រី
ដោយយើងឃើញត្រីនៅតូបរបស់គាត់គឺមានច្រើនប្រភេទ គឺមានច្រើនប្រភេទ មានដូចជាត្រីរ៉ស់
ត្រីផ្ទក់ ត្រីអណ្តែង និងត្រីទីឡាប់យ៉ា និងត្រីទីឡាប់យ៉ា ពីព្រោះអ្នកទិញ
អ្នកខ្លះគាត់ចូលចិត្តញុំាត្រីប្រភេទនេះ អ្នកខ្លះគឺគាត់ញុំា ចូលចិត្តញុំាត្រីប្រភេទត្រីនោះ អញ្ចឹងដើម្បី
[...] ដើម្បីផ្គាប់ចិត្តភ្ញៀវឲ្យត្រូវ អ្នកលក់គាត់ត្រូវលក់ត្រីច្រើនប្រភេទ
ដើម្បីឲ្យអ្នកទិញគាត់ជ្រើសរើស។ អញ្ចឹងយើងឃើញនៅតូបរបស់គាត់ យើងឃើញមានឆត្រមួយ
ដែលគាត់ប្រើសម្រាប់ សម្រាប់ការពារកម្តៅថ្ងៃ ឬក៏ប្រើសម្រាប់ការពារនៅពេលដែលមានភ្លៀង
កុំឲ្យភ្លៀងនោះទទឹកកន្លែងលក់របស់គាត់។ ពីព្រោះនៅពេលដែលភ្លៀងទទឹកកន្លែងលក់របស់គាត់
គឺគាត់មិនអាចអាំងត្រីនោះបានទេ។ អញ្ចឹងយើងឃើញត្រីនោះ យើងឃើញមាន យើងឃើញ
យើងឃើញគាត់កំពុងតែអាំងនៅលើភ្លើង ដែលគាត់បានដាក់ភ្លើងល្មម និងយើងឃើញមានផ្សែង
យើងឃើញមានផ្សែងហុយចេញ យើងឃើញមានផ្សែងហុយទៅខាងលើជាមួយនឹងក្លិនឈ្ងុយ
ជាមួយនឹងក្លិនឈ្ងុយ។ បន្ទាប់ពីបុរសដែលគាត់ពាក់អាវដៃខ្លីពណ៌ពងមាន់នោះ
គាត់បានឃើញតូបលក់ត្រីអាំង ដែលមានក្លិនឈ្ងុយនោះ គាត់ក៏បានដើរចូលដើម្បីទិញត្រី
និងទិញបាយសម្រាប់អាហារថ្ងៃ សម្រាប់អាហារល្ងាចនេះ។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ គាត់ក៏បានដើរចូលដើម្បីសួរតម្លៃ ដើម្បីសួរតម្លៃអ្នកលក់
អញ្ចឹងអ្នកលក់នៅពេលដែលភ្ញៀវដើរចូល អ្នកលក់ក៏បានក្រោកឈរដើម្បីស្វាគមន៍
និងដើម្បីសួរភ្ញៀវថាតើគាត់ចង់បានត្រី គាត់ចង់បានត្រីអ្វី និងគាត់ចង់ និងគាត់ចង់បានបាយ
ដើម្បីញុំាជាមួយ និងគាត់ចង់បានបាយដើម្បីញុំាជាមួយនឹងត្រីនោះឬទេ?
អញ្ចឹងអ្នកលក់ត្រូវក្រោកឈរដើម្បីស្វាគមន៍ ដើម្បីស្វាគមន៍ភ្ញៀវ
អញ្ចឹងយើងឃើញក្រោយពេលដែលបុរសម្នាក់នោះ បានឃើញ បានឃើញត្រី
បានឃើញត្រីដែលមានក្លិនឈ្ងុយ បានឃើញត្រីអាំងដែលមានក្លិនឈ្ងុយ គាត់ក៏បានដើរចូលទៅ
គាត់ក៏បានដើរចូលទៅតូបនោះដើម្បីសួរតម្លៃ គាត់ក៏បានចង្អុលទៅត្រី ត្រីដែលកំពុងតែអាំងនោះ
ដោយយើងឃើញត្រីមានច្រើនប្រភេទ អញ្ចឹងគាត់ចង្អុលប្រហែលជា ចង្អុលទៅត្រី ត្រីរ៉ស់ ត្រីរ៉ស់
ដែលយើងឃើញត្រីនោះ[មាន]រាងធំដែរ។ អញ្ចឹង គាត់ក៏បានចង្អុលទៅត្រីរ៉ស់នោះ ដើម្បីចង់ដឹងតម្លៃ
អញ្ចឹងនៅពេលដែលគាត់សួរទៅអ្នកលក់ អ្នកលក់ក៏បានប្រាប់អំពីតម្លៃ ដោយត្រីរ៉ស់នោះគឺតម្លៃ ៨
ពាន់រៀល ដោយសារតែត្រីរ៉ស់នោះ គឺជាត្រី គឺ គឺជាត្រីស្រស់ គឺជាត្រីស្រស់ គឺជាត្រីស្រស់
និងធម្មជាតិ ដូច្នេះគឺមានតម្លៃ ៨ ពាន់រៀល។
អញ្ចឹងនៅពេលដែលបុរសម្នាក់នោះគាត់បានដឹងអំពីតម្លៃត្រីនោះ គាត់ក៏បានយកត្រីនោះ
គាត់ក៏បានប្រាប់អ្នកលក់ឲ្យខ្ចប់ត្រីនោះឲ្យគាត់មួយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ គាត់ក៏បានប្រាប់អ្នកលក់ឲ្យខ្ចប់បាយចំនួន ២ ប្រអប់ឲ្យគាត់ ឲ្យគាត់។ ពីព្រោះប្រហែលជានៅផ្ទះរបស់គាត់មិនបានធ្វើម្ហូប និងក៏មិនបានដាំបាយដែរ។ ដូច្នេះគាត់ត្រូវទិញម្ហូប និងបាយ ដើម្បីញ៉ាំសម្រាប់អាហារពេលល្ងាចរបស់គាត់ អញ្ចឹងគាត់បានប្រាប់អ្នកលក់ឲ្យខ្ចប់បាយចំនួន ២ ប្រអប់។ ជាទូទៅម្ហូបអាហារដែលលក់នៅតាមចិញ្ចើមផ្លូវគឺអត់ថ្លៃទេ ដែលជាក់ស្តែងបាយ ១ ប្រអប់គឺតម្លៃត្រឹមតែ ១ ពាន់រៀល អញ្ចឹងបាយ ២ ប្រអប់គឺតម្លៃ ២ ពាន់រៀល បូកជាមួយនឹងត្រីដែលតម្លៃ ៨ ពាន់រៀល គឺ គឺ[មាន] គឺចំណាយតែ ១ ម៉ឺនរៀល អាចញ៉ាំ គឺចំណាយតែ ១ ម៉ឺនរៀល គឺគាត់អាចញ៉ាំឆ្អែត និងជាមួយ គឺគាត់អាចញ៉ាំឆ្អែត ជាមួយនឹង ជាមួយនឹងត្រីដែលមានរសជាតិឆ្ងាញ់។ ដូច្នេះក្រោយពេលដែលបុរសម្នាក់នោះ គាត់ប្រាប់ទៅអ្នកលក់ឲ្យខ្ចប់បាយចំនួន ២ ប្រអប់ អ្នកលក់ក៏បានរៀបចំ និងខ្ចប់បាយចំនួន ២ ប្រអប់ឲ្យទៅបុរសម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ៥ ក្រោយពេលដែលអ្នកលក់ខ្ចប់បាយចំនួន ២ ប្រអប់រួចរាល់ហើយ អ្នកលក់ក៏បាន ក៏បានយកកាសែត ១ សន្លឹក ដើម្បីខ្ចប់ត្រីដែលឆ្អិនហើយ ដើម្បីខ្ចប់ឲ្យបុរសម្នាក់នោះ។ អញ្ចឹងជាទូទៅត្រីយើងអាចដាក់ចូលទៅក្នុងថង់ និងយើងអាចខ្ចប់ដោយប្រើក្រដាសកាសែត ពីព្រោះប្រសិនបើយើងមិនបានខ្ចប់វាទេ ត្រីនឹងអាចត្រជាក់និងអត់មានរសជាតិឆ្ងាញ់ ប៉ុន្តែបើសិនជាយើងខ្ចប់វាត្រីនឹង ត្រីនោះនៅតែក្តៅ បើទោះបីជាយើងយកទៅញ៉ាំនៅផ្ទះក៏ដោយ។ ពីព្រោះយើងបានខ្ចប់វា ដូច្នេះចំហាយមិនបានចេញទៅខាងក្រៅទេ អញ្ចឹងវានៅងំនៅខាងក្នុងក្រដាសនោះ និងត្រីនោះនឹងនៅតែក្តៅ និងមានរសជាតិឆ្ងាញ់។ អញ្ចឹងអ្នកលក់បានយកក្រដាសកាសែត យកក្រដាស អ្នកលក់បានយកក្រដាសកាសែត និងត្រីដើម្បីយកមកខ្ចប់ជូនភ្ញៀវ។ អញ្ចឹងគាត់បានយកកាសែតរុំត្រីនោះ និងបានរៀបចំខ្ចប់យ៉ាងស្អាតដើម្បី ដើម្បីប្រគល់ឲ្យភ្ញៀវ។

បន្ទាប់មកទៀតរូបភាពទី ៦ ក្រោយពេលដែលអ្នកលក់បានរុំត្រីនោះដោយប្រើកាសែត ដោយប្រើក្រដាសកាសែត គាត់ក៏បានយកថង់យួរដៃមួយទៀត ដើម្បីដាក់របស់ទាំងអស់នោះចូលគ្នា ដោយយើងឃើញគាត់រុំត្រីជាមួយនឹងកាសែត គាត់ដាក់ចូលទៅក្នុងថង់ ជាមួយនឹង ជាមួយនឹងបាយសចំនួន ២ ប្រអប់ និងបន្លែដែលញ៉ាំជាមួយនឹងត្រីនោះ ដែលបន្លែរួមមានសាលាដ ត្រសក់ និងជីរ អញ្ចឹងបានដាក់ចូលទៅក្នុង បានដាក់ចូលទៅក្នុង បានដាក់ចូលទៅក្នុងថង់នោះ ដើម្បីញ៉ាំជាមួយនឹងត្រី។ នឹងបន្ទាប់មកគាត់ក៏ខ្ចប់ទឹកជ្រលក់ដែលយើងហៅថាទឹកត្រីផ្អែម

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ទឹកត្រីកោះកុង ដើម្បីជ្រលក់ជាមួយនឹងបន្លែ ជាមួយនឹងត្រី។ អញ្ចឹងគាត់បានខ្ចប់ទឹកជ្រលក់នោះ ១ ១ ថង់ ១ ថង់ធំ ដើម្បីអាចញ៉ាំល្មម ដើម្បីអាច ដើម្បីអាចញ៉ាំល្មមជាមួយនឹងត្រី និងជាមួយនឹងបន្លែ ប្រសិនបើយើងដាក់ទឹកជ្រលក់តិចពេក អាចញ៉ាំអត់គ្រប់ អញ្ចឹងយើងត្រូវ យើងត្រូវលៃយ៉ាងណាគឺដាក់ឲ្យល្មមជាមួយនឹងត្រី ជាមួយនឹងបន្លែ។ អញ្ចឹងយើងឃើញទឹកជ្រលក់នោះដូចជាមានម្ទេសពណ៌បៃតងដាក់ចូលទៅខាងក្នុងផង ពីព្រោះពេលខ្លះនៅពេលដែលយើងញ៉ាំទឹកត្រីផ្អែម នៅពេលដែលទឹកត្រីនោះមានរសជាតិហឹរបន្តិច គឺធ្វើឲ្យ គឺធ្វើឲ្យអាហាររបស់យើងមានរសជាតិឆ្ងាញ់ មានរសជាតិឆ្ងាញ់ និងជាពិសេសនៅពេលដែលយើងញ៉ាំត្រីផ្ទាប់ជាមួយបន្លែ ជាមួយនឹងទឹកត្រីផ្អែម មានអារម្មណ៍ថាម្ហូបនោះគឺឆ្ងាញ់ មានអារម្មណ៍ថាម្ហូបនោះគឺឆ្ងាញ់ អញ្ចឹងអ្នកលក់គាត់បានរៀបចំ រៀបចំដាក់ រៀបចំដាក់ត្រី ដាក់បន្លែ និងដាក់ទឹកជ្រលក់ចូលទៅក្នុងថង់មួយ ដើម្បីងាយស្រួល ដើម្បីងាយស្រួលយួរត្រលប់ទៅផ្ទះ។

បន្ទាប់មកទៀតរូបភាពទី ៧
ក្រោយពេលដែលអ្នកលក់បានរៀបចំម្ហូបអាហារដាក់ចូលទៅក្នុងថង់យួរដៃរួចរាល់ហើយ អ្នកលក់ក៏បានហុចថង់នោះប្រគល់ជូនទៅបុរសម្នាក់នោះ អញ្ចឹងបុរសម្នាក់នោះក៏បានប្រគល់លុយ គាត់បានដកលុយនោះចេញពីហោប៉ៅរបស់គាត់ប្រគល់ទៅឲ្យអ្នកលក់ និងអ្នកលក់ក៏បានទទួលលុយនោះ ដោយលុយនោះគឺ ១ ម៉ឺនរៀល ដោយសារតែត្រីមួយ ដោយសារតែត្រីមួយតម្លៃ ៨ ពាន់រៀល បូកជាមួយនឹងបាយ ២ ប្រអប់ ២ ពាន់រៀល ដូច្នេះតម្លៃទាំងអស់គឺ តម្លៃទាំងអស់គឺ ១ ម៉ឺនរៀល។ អញ្ចឹងប្រសិនបើគាត់ឲ្យ ប្រសិនបើគាត់ឲ្យលុយ ១ ម៉ឺនរៀលទៅកាន់អ្នកលក់ អ្នកលក់គឺគាត់អត់អាប់ឲ្យវិញទេ ពីព្រោះ ពីព្រោះតម្លៃទាំងអស់គឺ ១ ម៉ឺនរៀល ប្រសិនបើគាត់ឲ្យក្រដាស ក្រដាស ២ ម៉ឺនរៀលទៅអ្នកលក់ អញ្ចឹងអ្នកលក់គាត់នឹងអាប់លុយជូន ១ ម៉ឺន[រៀល] ១ ម៉ឺនរៀលវិញ។ អញ្ចឹងប្រសិនបើគាត់ឲ្យលុយដុំទៅអ្នកលក់ អ្នកលក់គឺអាប់លុយឲ្យទៅអ្នកទិញវិញ។ ប៉ុន្តែជាក់ស្តែងនៅក្នុងរូបភាពនេះ ដោយសារតែតម្លៃតែ ១ ម៉ឺនរៀល និងដោយសារតែគាត់មានលុយ ១ ម៉ឺនរៀលផងដែរ។ អញ្ចឹងគាត់បានហុចឲ្យអ្នកលក់ អញ្ចឹងអ្នកលក់ក៏បានយកលុយនោះទុក និងមិនបានអាប់ និងមិនបានអាប់លុយឲ្យអ្នកទិញទេ។ ពីព្រោះដោយសារតែលុយនោះគឺក្រដាស ១ ម៉ឺនរៀល។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ បុរសម្នាក់នោះគាត់ក៏បានយួរថង់ ថង់ដែលមានបន្លែមានត្រី និងមានបាយចំនួន ២ ប្រអប់នោះ ត្រលប់មកផ្ទះរបស់គាត់វិញ ដោយយើងឃើញនៅផ្ទះរបស់គាត់ យើងឃើញនៅក្បែរទ្វារផ្ទះរបស់គាត់ យើងឃើញមានដើមផ្កា ដើមផ្កា ១ ដើមដែលដាំនៅក្នុង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលដាក់នៅក្នុងថូ ឬក៏ដាំនៅក្នុងផើងផ្កាដែលគាត់ដាក់នៅក្បែរ
ដែលគាត់ដាក់នៅក្បែរទ្វារផ្ទះរបស់គាត់។
អញ្ចឹងយើងឃើញគាត់ដើរចូលផ្ទះរបស់គាត់ដោយទឹកមុខញញឹម
ដោយសារតែគាត់មានម្ហូបដែលមានរសជាតិឆ្ងាញ់ សម្រាប់អាហារថ្ងៃនេះ
នឹងដោយសារម្ហូបរបស់គាត់ថ្ងៃនេះគឺចំណាយតិច។

បន្ទាប់មកទៀតគឺរូបភាពទី ៩ រូបភាពទី ៩ នៅពេលដែលគាត់ដើរចូលទៅក្នុងផ្ទះ
នៅពេលដែលគាត់ដើរចូលទៅក្នុងផ្ទះ គាត់ក៏បាន គាត់ក៏បានដាក់ថង់ម្ហូប និងបាយរបស់គាត់ចុះ
បន្ទាប់មកគាត់ក៏ដើរទៅយកកន្ទេល ឬក៏ក្រណាត់ក្រាលសម្រាប់ញ៉ាំបាយ គាត់ក៏បានយកមកក្រាល
គាត់ក៏បានយកមកក្រាលនៅលើឥដ្ឋដើម្បីញ៉ាំ ញ៉ាំបាយជុំគ្នា អញ្ចឹងនៅផ្ទះរបស់គាត់គឺអត់ប្រើតុ
និងកៅអីទេ។ គឺនៅពេលញ៉ាំបាយគឺគាត់ប្រើកន្ទេល
ឬក៏ក្រណាត់សម្រាប់ក្រាលនៅលើឥដ្ឋដើម្បីញ៉ាំបាយ អញ្ចឹងក្រណាត់ ឬក៏កន្ទេលនោះគឺមូល
អញ្ចឹងនៅពេលដែលយើងចង់ក្រាលនៅលើឥដ្ឋគឺយើងត្រូវលាវាដាក់នៅលើឥដ្ឋ។
អញ្ចឹងគាត់បានលាកន្ទេល ឬក៏ក្រណាត់នោះដាក់នៅលើឥដ្ឋ ដើម្បីញ៉ាំ ដើម្បីញ៉ាំបាយ
បន្ទាប់មកទៀត មិត្តស្រីរបស់គាត់ក៏បានដើរទៅផ្ទះបាយ ដើម្បីយកចាន
ឬក៏ដើម្បីលើកចានយកមកដាក់ម្ហូប អញ្ចឹងយើងនឹងឃើញនៅក្នុងដៃទាំង ២ របស់គាត់មានកាន់ចាន
មានកាន់សម និងស្លាបព្រា ដើម្បីយកមកញ៉ាំបាយ ដើម្បីយកមកញ៉ាំបាយជុំគ្នា។
ដែលយើងឃើញមិត្តស្រីរបស់គាត់ ពាក់អាវយឺតពណ៌សដៃខ្លី ជាមួយនឹងខោជើងវែងពណ៌ខ្មៅ
និងសក់របស់គាត់ចងលើកឡើងទៅលើ។ អញ្ចឹងគាត់
នៅពេលដែលគាត់ឃើញមិត្តប្រុសរបស់គាត់បានទិញម្ហូបអាហារ និងបាយសម្រាប់អាហារពេលល្ងាច
គាត់ក៏បានដើរទៅយកចាន យកស្លាបព្រា យកសម ដើម្បី
ដើម្បីយកមកដាក់ម្ហូបអាហារនឹងញ៉ាំជុំគ្នា។ អញ្ចឹងពួកគាត់គឺចែកការងារធ្វើ ចែកការងារគ្នាធ្វើ
អញ្ចឹងមិត្តប្រុសរបស់គាត់បានក្រាលក្រណាត់ ឬក៏កន្ទេលនៅលើឥដ្ឋ
មិត្តស្រីរបស់គាត់ដើរទៅយកចាន សម ស្លាបព្រា ដើម្បីញ៉ាំជុំគ្នា។

រូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលគាត់ក្រាលកន្ទេល ឬក៏ក្រណាត់នោះរួចរាល់ហើយ
ពួកគាត់ទាំង ២ ក៏បានអង្គុយ និងបានរៀបចាន និងបានរៀបចាន និងរៀបសម ស្លាបព្រា
ដើម្បីដាក់ម្ហូបញ៉ាំ ញ៉ាំទាំងអស់គ្នា អញ្ចឹងយើងឃើញពួកគាត់ទាំង ២
កំពុងតែរៀបចានដាក់នៅខាងមុខគាត់ ដោយយើងឃើញ ដោយយើងឃើញបុរសម្នាក់នោះ
គឺគាត់កាន់នៅខាង នៅខាងស្តាំ នៅខាងស្តាំដៃរបស់គាត់គឺគាត់កាន់ចានបាយ
នៅខាងឆ្វេងដៃរបស់គាត់គឺក្នុង នៅក្នុងដៃខាងឆ្វេងរបស់គាត់គឺកាន់សម និងស្លាបព្រា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងដៃខាងស្ដាំរបស់គាត់គឺកាន់ចានបាយ និងមិត្តស្រីរបស់គាត់ក៏កាន់ ក៏កាន់ចានបាយ និងដាក់ចានបាយនោះនៅលើភ្លៅរបស់គាត់ នៅលើភ្លៅរបស់គាត់ និងមានចានបាយ ២ ទៀត និងសម និងស្លាបព្រានៅក្បែរនោះផងដែរ។ នឹងយើងឃើញថង់ម្ហូបអាហារ គឺដាក់នៅខាងក្រោយមិត្តស្រីរបស់គាត់ ដោយយើងឃើញមានផ្សែងហុយចេញមកខាងក្រៅ ដោយមានក្លិនឈ្ងុយពី មានក្លិនឈ្ងុយពីត្រីអាំង មានក្លិនឈ្ងុយពីត្រីអាំង ធ្វើឲ្យពួកគាត់ទាំង ២ ឃ្លានយ៉ាងខ្លាំង ពីព្រោះដោយសារតែក្លិនឈ្ងុយរបស់ត្រីអាំង។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ រូបភាពទី ១១ មិត្តប្រុសរបស់គាត់ក៏បានយក ក៏បានយកត្រី ក៏បានយកត្រីដាក់ចូលទៅក្នុងចាន ដើម្បីញ៉ាំ យកត្រីដាក់ចូលទៅក្នុងចានដើម្បីញ៉ាំជាមួយគ្នា ដោយយើងឃើញនៅពេលដែលគាត់ដាក់ នៅពេលដែលគាត់ហែក ហែកក្រដាសកាសែតនោះចេញ ហែកក្រដាសកាសែតនោះចេញ និងដាក់ត្រីចូលទៅក្នុងចាន យើងឃើញមានផ្សែងហុយចេញមកខាងលើជាមួយនឹងក្លិនឈ្ងុយ ជាមួយនឹងក្លិនឈ្ងុយ អញ្ចឹងគាត់បានលើកចាននោះដាក់នៅកណ្ដាល ដាក់នៅកណ្ដាល ដែលមានចានបាយនៅសងខាងនោះផងដែរ។

បន្ទាប់មកទៀត បន្ទាប់មកទៀត រូបភាពទី ១២ រូបភាពទី ១២ ក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ដាក់ត្រីដែលមានក្លិនឈ្ងុយនោះ នៅកណ្ដាល នៅកណ្ដាលរួចរាល់ហើយ គាត់ក៏បាន គាត់ក៏បានយកថង់ ថង់ទឹកជ្រលក់ ដែលយើងហៅថាទឹកត្រីផ្អែម ជាមួយនឹងម្ទេសពណ៌បៃតង។ អញ្ចឹងគាត់ក៏បានស្រាយថង់នោះ និងចាក់ទឹកជ្រលក់នោះចូលទៅក្នុងចានទឹកជ្រលក់ ចូលទៅក្នុងចានទឹកជ្រលក់ ដើម្បីញ៉ាំជាមួយនឹងត្រី និងជាមួយនឹងបន្លែ។ អញ្ចឹងជាទូទៅនៅពេលដែលយើងទិញម្ហូបអាហារនៅតាមផ្លូវ អ្នកលក់គឺខ្ចប់ម្ហូបអាហារនោះនៅក្នុងថង់ ឬក៏នៅក្នុងក្រដាសកាសែត ពីព្រោះអ្នកលក់មិនអាចឲ្យចានទៅកាន់អ្នកទិញបានទេ។ អញ្ចឹងពីព្រោះ ពីព្រោះការខ្ចប់ដោយប្រើថង់ ឬក្រដាសកាសែតគឺងាយស្រួលយួរ។ អញ្ចឹងនៅពេលដែលយើងយកមកដល់ផ្ទះ យើងត្រូវចាក់ម្ហូបអាហារនោះចូលទៅក្នុងចាន និងជាទូទៅយើងអត់ញ៉ាំម្ហូបអាហារនោះនៅក្នុងថង់ ឬក៏យើងញ៉ាំត្រីនៅក្នុងកាសែតនោះទេ។ គឺមើលទៅ គឺយើង គឺយើងមើលទៅគឺអត់ល្អមើល និងមើលទៅហាក់ [...] ហាក់ដូចជាបញ្ជាក់ថា យើងគឺជាមនុស្សខ្ជិលម្នាក់ដែលគ្រាន់តែម្ហូបអាហារ ដែលដាក់នៅក្នុងចានគឺយើងខ្ជិលដាក់ គឺយើងញ៉ាំនៅក្នុងថង់ អញ្ចឹងយើងមើលទៅគឺអត់ល្អមើល អញ្ចឹងជាទូទៅនៅពេលដែល ដែលយើងទិញម្ហូបអាហារពីខាងក្រៅ គឺយើងត្រូវចាក់ម្ហូបអាហារនោះ រៀបចំចូលទៅក្នុង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវចាក់ម្ហូបអាហារនោះចូលទៅក្នុងចាន និងរៀបចំវាឲ្យបានស្អាត និងរៀបចំវាឲ្យបានស្អាត ពីព្រោះនៅពេលដែលយើងរៀបចំស្អាត មើលទៅគួរឲ្យចង់ញ៉ាំ និងយើងញ៉ាំបានច្រើន។

អញ្ចឹងរូបភាពទី ១៣ ក្រោយពេលដែលគាត់ដាក់ត្រីនៅក្នុងចាន ដាក់បន្លែដូចជា សាលាដ ដូចជាសាលាដ និងត្រសក់ និងជីរ [ដាក់រៀប] រៀបដាក់នៅលើចាន និងទឹកជ្រលក់ចាក់ចូលទៅក្នុងចានរួចរាល់ហើយ ពួកគាត់ទាំង ២ ក៏បាន ក៏បាន[ដាក់] ក៏បានចាក់បាយចូលទៅក្នុងចានបាយរបស់គាត់ ដើម្បី ដើម្បីញ៉ាំ ដើម្បីញ៉ាំ ដើម្បីញ៉ាំជាមួយនឹងត្រី និងបន្លែនោះ។ អញ្ចឹងយើងឃើញមិត្តស្រីរបស់គាត់គឺកំពុងតែអង្គុយ គឺកំពុងតែអង្គុយចាំញ៉ាំ ពីព្រោះដោយសារតែមិត្តប្រុសរបស់គាត់គឺកំពុងតែរៀបចំម្ហូបនោះចាក់ចូលទៅក្នុង ចាក់ចូល និងរៀបចំទៅក្នុងចាន រៀបចំទៅក្នុងចាន អញ្ចឹងពួកគាត់មិនទាន់ញ៉ាំនៅឡើយទេ។ ពួកគាត់រៀបចំ រៀបចំម្ហូបជាមុនសិន បន្ទាប់មកទើបពួកគាត់ញ៉ាំជាមួយគ្នា។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ គាត់ក៏បានយកប្រអប់បាយ និងបើកប្រអប់បាយនោះ ដើម្បីចាក់បាយចូលទៅក្នុងចាន ដើម្បីចាក់បាយចូលទៅក្នុងចាន ដោយយើងឃើញដៃទាំង ២ របស់គាត់ ដៃម្ខាងកាន់ប្រអប់ ដៃម្ខាងទៀតគឺកំពុងតែបើកប្រអប់នោះ ដើម្បីដាក់បាយចូលទៅក្នុងចាន។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ គាត់ក៏បាន គាត់ក៏បានបេះសាច់ត្រីនោះ ដោយយើងឃើញគាត់ប្រើសម និងស្លាបព្រា គាត់ប្រើសម និងស្លាបព្រា។ ជាទូទៅប្រសិនបើយើងញ៉ាំតែស្លាបព្រា គឺពិបាក ដោយសារតែយើងញ៉ាំតែស្លាបព្រាយើងពិបាកបេះសាច់ត្រីនោះ។ ប៉ុន្តែប្រសិនបើយើងប្រើសម និងស្លាបព្រាគឺងាយស្រួល យើងអាចប្រើសមឆ្កឹះ ឆ្កឹះសាច់ត្រីនោះ និងយើងអាចប្រើស្លាបព្រាសម្រាប់ជួយផងដែរ។ និងនៅពេលដែលយើងឆ្កឹះសាច់ត្រីហើយ យើងអាចដាក់សាច់ត្រីនោះចូលទៅក្នុងស្លាបព្រា និងញ៉ាំយ៉ាងងាយស្រួល។ អញ្ចឹងយើងឃើញត្រីនោះគឺមានក្លិនឈ្ងុយ អញ្ចឹង មានក្លិនឈ្ងុយ អញ្ចឹងក្រោយពេលដែលគាត់រៀបចំម្ហូប និងត្រីនោះដាក់ចូលទៅក្នុងចានរួចរាល់ហើយ អញ្ចឹងធ្វើឲ្យគាត់មានអារម្មណ៍ថាឃ្លានយ៉ាងខ្លាំង។ ពីព្រោះដោយសារតែក្លិនឈ្ងុយពីត្រីនោះ។ អញ្ចឹងគាត់ក៏បាន គាត់ក៏បានប្រើសម គាត់ក៏បានប្រើសម ដោយដៃម្ខាងគឺកាន់សម ដៃម្ខាងគឺកាន់ស្លាបព្រា។ អញ្ចឹងគាត់បានប្រើសមចាក់យកសាច់ត្រីនោះយកមកញ៉ាំ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៦ [...] រូបភាពទី ១៦ គាត់ក៏បានយកសាច់ត្រីដែលគាត់បានអ៊ាំងនោះ
ជ្រលក់ជាមួយនឹងទឹកត្រីផ្អែម ទឹកត្រីផ្អែម ដែលមាន ដែលមាន ដែលមានរសជាតិហឹរបន្តិច
ជាមួយនឹងម្ទេសពណ៌បៃតង អញ្ចឹងគាត់ ក្រោយពេលដែលគាត់បេះត្រីនោះហើយ
គាត់ក៏បានយកជ្រលក់ជាមួយនឹងទឹកត្រីផ្អែមនោះ បន្ទាប់មកគាត់ក៏បាន គាត់ក៏បានយកបន្លែ
គាត់ក៏បានយកបន្លែជ្រលក់ជាមួយនឹងទឹកត្រី ញ៉ាំជាមួយនឹងត្រីនោះផងដែរ។
ពីព្រោះពេលខ្លះទឹកត្រីផ្អែម ភាគច្រើនគឺយើងញ៉ាំត្រីផ្ទាប់ជាមួយនឹងបន្លែ
ពីព្រោះដើម្បីឲ្យម្ហូបនោះកាន់តែមានរសជាតិឆ្ងាញ់ កាន់តែមានរសជាតិឆ្ងាញ់ និងជាមួយនឹង
ជាមួយនឹងរសជាតិទឹកត្រីផ្អែមរាងហឹរបន្តិច ដូច្នេះធ្វើឲ្យពួកគាត់គឺញ៉ាំច្រើន ធ្វើឲ្យគាត់ញ៉ាំច្រើន។

ដោយរូបភាពទី ១៧ ក្រោយពេលដែលពួកគាត់ ក្រោយពេលដែលពួកគាត់ញ៉ាំហើយ មាន[អារម្មណ៍]
ពួកគាត់មានអារម្មណ៍ថាឆ្អែត ដោយសារតែត្រីមានរសជាតិឆ្ងាញ់
និងបន្លែជាមួយនឹងទឹកត្រីផ្អែមនោះច្រើនផង ដូច្នេះគឺគាត់ញ៉ាំច្រើន គាត់ញ៉ាំច្រើន
គឺគាត់មានអារម្មណ៍ថាឆ្អែត អញ្ចឹងយើងឃើញ
យើងឃើញនៅក្នុងចានគឺត្រីគឺនៅសល់តែឆ្អឹងនិងក្បាល និងបន្លែ និងបន្លែដែលមានសាលាដ ត្រសក់
និងជីរ និងជាមួយនឹងទឹកត្រី គឺ[ក៏] និងទឹកត្រីក៏បានអស់ដែរ ក៏បានអស់ដែរ។ អញ្ចឹងធ្វើឲ្យពួកគាត់
អញ្ចឹងមានន័យថាពួកគាត់ញ៉ាំ ញ៉ាំម្ហូប និងបាយទាំងនោះអស់ អញ្ចឹងពួកគាត់ទាំង ២
មានអារម្មណ៍ថាឆ្អែត។ អញ្ចឹងយើងឃើញបុរសម្នាក់នោះ គឺគាត់ ដោយសារតែគាត់ឆ្អែតពេក
អញ្ចឹងធ្វើឲ្យគាត់ពិបាកអង្គុយ។ យើងឃើញគាត់ គាត់ដាក់ដៃទៅខាងក្រោយ ដើម្បីផ្អៀងខ្លួនបន្តិច
និងគាត់យកដៃអង្អែលពោះរបស់គាត់។ និងគាត់អង្គុយ អង្គុយដោយដាក់
ដោយដាក់ជើងរបស់គាត់ម្ខាងបញ្ឈរ ដោយដាក់ អញ្ចឹងមានន័យថាគាត់អង្គុយបញ្ឈរជង្គង់
អញ្ចឹងគាត់ គាត់រៀងផ្ទេរ គាត់រៀង [...] គាត់រៀងផ្ទេរខ្លួនរបស់គាត់ទៅក្រោយបន្តិច
ដោយសារតែគាត់ឆ្អែតពេក និងពិបាកអង្គុយ។ មិត្តស្រីរបស់គាត់ដូចគ្នាដែល មិត្តស្រី[របស់]
មិត្តស្រីរបស់គាត់គឺអង្គុយបត់ជើង។ ជាទូទៅគឺមនុស្សស្រីគឺអង្គុយបត់ជើង
មនុស្សប្រុសគឺអង្គុយពែនភ្នែននៅពេលដែលញ៉ាំបាយ។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ១៧
នេះ យើងឃើញមិត្តស្រីរបស់គាត់ គឺអង្គុយបត់ជើងញ៉ាំបាយ មិត្តប្រុសរបស់
មិត្តប្រុសរបស់គាត់គឺអង្គុយពែនភ្នែន។ ប៉ុន្តែដោយសារតែគាត់ញ៉ាំបាយហើយ
គាត់មានអារម្មណ៍ថាឆ្អែត គាត់ក៏[...] គាត់ក៏ គាត់ក៏អង្គុយ គាត់ក៏អង្គុយបញ្ឈរ បញ្ឈរក្បាលជង្គង់វិញ
ដោយសារតែអង្គុយបត់ជើងមាន[អារម្មណ៍] ដោយសារតែអង្គុយពែនភ្នែនមានអារម្មណ៍តឹងពោះពេក
និងពិបាកអង្គុយ។ អញ្ចឹងយើងឃើញ អញ្ចឹង ការញ៉ាំមនុស្សស្រីនិងមនុស្សប្រុសគឺអង្គុយខុសគ្នា
មនុស្សស្រីអង្គុយបត់ជើង មនុស្សប្រុសគឺអង្គុយពែនភ្នែន។ អញ្ចឹងពួកគាត់ទាំង ២ អង្អែលពោះ
ដោយសារតែពួកគាត់ ដោយសារតែពួកគាត់ញ៉ាំឆ្អែតពេក។ អញ្ចឹងមានន័យថា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អាហារពេលល្ងាចរបស់គាត់ ដែលគាត់បានទិញនៅតាមចិញ្ចើមថ្នល់
ដោយមានត្រីអាំងជាមួយនឹងបន្លែ ជាមួយនឹងបន្លែ និងទឹកត្រីផ្អែម ធ្វើឲ្យគាត់ទាំង ២ ញ៉ាំ[យ៉ាង]
ធ្វើឲ្យគាត់ទាំង ២ ញ៉ាំច្រើនរហូតដល់ឆ្អែតជ្រុល និងម្ហូបទាំងអស់នោះគឺមានរសជាតិឆ្ងាញ់
និងតម្លៃគឺអត់ថ្លៃទេ ត្រឹមតែ ១ ម៉ឺនរៀល។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.